**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
*Kingdom of Wonder*

**ក្រសួងទេសចរណ៍**

**លេខ** ០៨៥ ពណសរ

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មិថុ ឆ្នាំ២០១៥

**ជម្រាបជូន**

**លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា**

**កម្មវត្ថុ:** អញ្ជើញចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការអន្តរក្រសួង. ដើម្បីគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ខេត្តឧត្តរមានជ័យ។

**យោង:** សេចក្តីសម្រេចលេខ ១៥២សសរ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន **លោក** ជ្រាបថា ដើម្បីទទួលបានជោគជ័យក្នុងការគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែងទាំង១៤ចំណុចឲ្យបានរលូន និងប្រកបដោយប្រសិទ្ធភាព គណៈកម្មការអន្តរក្រសួង នឹងរៀបចំកិច្ចប្រជុំ និងធ្វើទស្សនកិច្ចជាក់ស្តែង ដែល**ប្រព្រឹត្តទៅនៅថ្ងៃទី០៧-០៨ ខែកក្កដា ឆ្នាំ២០១៥ វេលាម៉ោង ០៨:០០នាទីព្រឹក នៅសាលាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ** (សូមជូនភ្ជាប់ជាមួយនូវកម្មវិធីចំនួន ០១ច្បាប់)។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអញ្ជើញចូលរួមក្នុងកិច្ចប្រជុំខាងលើតាមការគួរ។

សូម **លោក** ទទួលនូវសេចក្តីរាប់អានដ៏ស្មោះពីខ្ញុំ។

**បញ្ជាក់: ចំពោះមធ្យោបាយធ្វើដំណើរ ហូបចុក និងស្នាក់នៅ ជាបន្ទុករបស់សាមីក្រសួង។*

*សូមមេត្តាឆ្លើយតប:*
*- ០១២ ៦៧៦ ៣៦៤*
*- ០៨៩ ២៨៥ ៧២៥/០៩២ ២៥៦ ៨៦៧*

**ប្រធានគណៈកម្មការអន្តរក្រសួង**

**ថោង ខុន**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**